ជូនចំពោះ មាតាបិតា និង ក្រុមគ្រួសារ៖

ការខិតខំរបស់លោកអ្នកចំពោះ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា គឺជា កម្លាំង និង តម្លៃ ដែលយើងខ្ញុំជឿថា យើងខ្ញុំត្រូវជូនដំណឹងដល់លោកអ្នក អំពីការអភិវឌ្ឍន៍សំខាន់ៗនៅក្រសួងអប់រំរបស់យើង។ ដោយមូលហេតុនេះហើយ ដែលយើងខ្ញុំទាក់ទងទៅលោកអ្នកឲ្យបានដឹងអំពីការអភិវឌ្ឍន៍ដ៏សំខាន់ ដែលទាក់ទងនឹង សហជីពគ្រូបង្រៀននៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (PFT)។

បន្ទាប់ពីបានចរចាជាមួយ PFT អស់រយៈពេលជិតពីរឆ្នាំ ដើម្បីអភិវឌ្ឍកិច្ចព្រមព្រៀងដ៏ទូលំទូលាយ ដែលរួមមានទាំង អត្ថប្រ យោជន៍ផ្នែកសុខភាពរបស់ PFT និង ការជួយចេញប្រាក់ខ្លះ ដូចបុគ្គលិកផ្សេងៗទៀតរបស់យើង និង បុគ្គលិកនៅក្រសួងអប់រំឯទៀត ទូទាំងរដ្ឋ និង ទូទាំងប្រទេស យើងនៅតែមិនអាចចុះកិច្ចព្រមព្រៀង។

ក្នុងគ្រាជាមួយគ្នានេះ សភាពការណ៍នៅ សាលា និង ថ្នាក់រៀន របស់យើង មានការខ្វះខាត ហើយដោយសារគ្មានប្រាក់ជំនួយបន្ថែម គឺកាន់តែមានសភាពដុនដាបថែមទៀត។ ថ្ងៃនេះ គណកម្មាធិការកែទម្រង់សាលារៀន បានប្រើសិទ្ធិអំណាចដើម្បីលប់កិច្ចព្រមព្រៀងរបស់ក្រសួង ជាមួយនឹង PFT ដើម្បីតម្រូវឲ្យមានការផ្លាស់ប្តូរផែនការផ្នែកសុខភាព និង ការជួយចេញប្រាក់ខ្លះពីបុគ្គលិក។

សកម្មភាពថ្ងៃនេះ នឹងបញ្ជូនប្រាក់ចំនួន ៤៣,៨ លាន ដុល្លារ ទៅសាលារបស់យើង ក្នុងរយៈពេលនៃឆ្នាំសិក្សានេះ។ បន្ថែមពីលើនេះ ក្រសួងអប់រំនឹងសន្សំប្រាក់បានចំនួន ១០ លាន ដុល្លារ បន្ថែមទៀត ដែលជាប្រាក់ជំនួយបានមកពីរដ្ឋសហព័ន្ធ ដែលអាចប្រើដើម្បីឧបត្ថម្ភដល់ការបង្ហាត់បង្រៀន សម្រាប់សិស្សានុសិស្សរបស់យើងដែលត្រូវការជាងគេបំផុត។ ក្នុងរយៈពេលបួនឆ្នាំទៅមុខទៀត ចំនួនប្រាក់សន្សំនេះអាចមានចំនួនសរុបដល់ទៅ ១៩៨,៥ លាន ដុល្លារ សម្រាប់ការចំណាយទូទៅ និង ៤៧ លាន ដុល្លារ ជាប្រាក់ជំនួយបានមកពីរដ្ឋសហព័ន្ធ។ សូមមើលព័ត៌មានបន្ថែមអំពីប្រាក់ឧបត្ថម្ភដែលយើងប្រគល់ឲ្យទៅសាលាវិញ ដែលមានភ្ជាប់មកជាមួយនឹងលិខិតនេះ។

ការតម្រូវឲ្យ គ្រូ និង បុគ្គលិកដ៏ទៃទៀត ជួយចេញថ្លៃធានារ៉ាប់រងសុខភាពរបស់ពួកគេ គឺជាការផ្លាស់ប្តូរ និង ការលះបង់ ប៉ុន្តែការជួយចេញថ្លៃសម្រាប់ការធានារ៉ាប់រងសុខភាព គឺជាភាពជាក់ស្តែងនៅគ្រប់កន្លែងធ្វើការសព្វថ្ងៃ។ បុគ្គលិកដ៏ទៃទៀតរបស់ក្រសួង រួមទាំង នាយកសាលា កម្មករនៅតាមសាលា និង បុគ្គលិកនៅការិយាល័យកណ្តាល របស់យើង បានយល់ព្រមជួយចេញថ្លៃស្រដៀងគ្នានេះដែរ។

យើងខ្ញុំគាំទ្រសិទ្ធិរបស់បុគ្គលិកយើង ដែលតំណាងឲ្យដោយ PFT ហើយយើងខ្ញុំនៅតែខិតខំដើម្បីបង្កើតកិច្ចព្រមព្រៀងថ្មី អំពី ប្រាក់ខែ ច្បាប់ការងារ និង បញ្ហាផ្សេងៗទៀត តាមរយៈនៃការបន្តការចរចាគ្នាជាមួយនឹងសហជីព។

ការយកចិត្តទុកដាក់តែមួយគត់របស់យើង គឺផ្តល់បរិយាកាសសិក្សាដ៏ល្អបំផុតដល់សិស្សានុសិស្សទាំងអស់។ យើងខ្ញុំដឹងថា បុគ្គលិករបស់ក្រសួងទាំងអស់ ធ្វើការលះបង់យ៉ាងច្រើន ជារៀងរាល់ថ្ងៃ ដើម្បី សិស្សានុសិស្ស និង សាលា របស់យើង។ តែទោះជាយ៉ាងនេះក្តី ការខ្វះខាតថវិការ តម្រូវឲ្យមានការសម្រេចចិត្តដ៏លំបាក។

ខ្ញុំទទូចសូមឲ្យលោកអ្នកបន្តការគាំទ្ររបស់លោកអ្នក ហើយទាក់ទងទៅអ្នកតំណាងរបស់លោកអ្នក ដើម្បីទាមទារជាមួយ ខ្ញុំ និង គណកម្មាធិការកែទម្រង់សាលារៀន និង អ្នកដ៏ទៃទៀត ដើម្បីសុំប្រាក់បន្ថែម ដែលយើងត្រូវការជាចាំបាច់ និង រូបមន្តដ៏ត្រឹមត្រូវ សម្រាប់ការផ្តល់ប្រាក់ជំនួយដល់សាលារដ្ឋ តាមកម្រិតថ្នាក់រដ្ឋ។

សូមអរគុណចំពោះការបន្តការគាំទ្រ របស់លោកអ្នក។

ដោយសេចក្តីស្មោះស្ម័គ្រ
William R. Hite, Ed.D.